ភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

# ប្រកាសលេខ ០០៧ កសហវ.ប្រក

## ស្តីពីការសងប្រាក់ពន្ធ ចំពោះទំនិញនាំចូល

## ដែលជាប់អាករពន្ធខ្ពស់ហើយត្រូវនាំចេញទៅវិញ

* * * *

- បានឃើញ ព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និង នាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩៨ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៣ ។
- បានឃើញលិខិតលេខ ១៩៧ សរណក.ពយ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីផែនការ ការកែលំអ ប្រព័ន្ធពន្ធ និង អាករ ។

### សំរេច

ប្រការ ១ ៖ អោយទៅតាមថ្លៃលក់ទំនិញនៅលើទីផ្សារទំនិញនាំចូលមួយចំនួនដែលជាប់អាករខ្ពស់ហើយបាននាំចេញទៅវិញនោះ និងត្រូវបានសងប្រាក់ពន្ធវិញមានដូចខាងក្រោម ៖

- បារី ៥៥៥ , ម៉ាល់បូរ៉ូ , វីនស្តុន , កេន សងប្រាក់ពន្ធវិញ ៩៤ % នៃប្រាក់ពន្ធពន្ធ និង អាករ
- បារី ប្រភេទផ្សេងៗ សងប្រាក់ពន្ធវិញ ៦៥ % - ដ -
- ស្រាសេរី សងប្រាក់ពន្ធវិញ ៨៥ % - ដ -
- ប៉េបស៊ី សងប្រាក់ពន្ធវិញ ៧០ % - ដ -
- ម៉ាញ៉េតូហ្វូន សងប្រាក់ពន្ធវិញ ៦០ % - ដ -
- ស្រាបៀរ សងប្រាក់ពន្ធវិញ ៦៥ % - ដ -
- ស្រា សងប្រាក់ពន្ធវិញ ៨០ % - ដ -
- រថយន្តធុនតូចថ្មី សងប្រាក់វិញ ៩៥ % - ដ -
- ទោចក្រយានយន្តថ្មី សងប្រាក់ពន្ធវិញ ៨០ % - ដ -

ប្រការ ២ : ការអនុវត្តសងប្រាក់ពន្ធវិញ បានចំពោះតែទំនិញទាំងឡាយណាដែលនៅពេលនាំចូលបានបង់ពន្ធតាមតារាង ពន្ធគយថ្មីហើយនិងនាំចេញទៅវិញ ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ដោយគិតចាប់ពីថ្ងៃនាំចូល ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

* * * *

# និស្តិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

## ប្រកាស

ភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៩៣

**ប្រកាស លេខ : ១៩៤ ឧក.ប្រក**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការគ្រប់គ្រង ឧស្សាហកម្មតូច និង សិប្បកម្ម
- យោងលិខិតអនុញ្ញាតរបស់អភិបាលក្រុងភ្នំពេញលេខ ៧៦៣ ឧ អ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩១
- បានឃើញពាក្យស្នើសុំបន្តផលិតកម្ម សិប្បកម្មអិដ្ឋ ក្បឿង របស់លោក វ៉ុង ង៉ាក់សេង ចុះថ្ងៃទី ២៨ - ០៦ - ៩៣